ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គណបក្សសិទ្ធិមនុស្ស

បំរើ ការពារ កសាង

# កម្មវិធីនយោបាយជាអាទិភាព

## ៩ចំណុច និង ៥៥វិធានការ

**រដ្ឋាភិបាលរបស់ប្រជាពលរដ្ឋ**

# មាតិកាអត្ថបទ

ប្រវត្តិគណបក្សសិទ្ធិមនុស្ស.....................................................................................

១- ចក្ខុវិស័យ និង បេសកកម្ម..................................................................... ២

២- គោលបំណង........................................................................................ ២

៣- បាវចនា............................................................................................. ២

៤- រូបសញ្ញា............................................................................................. ២

៥- មាគ៌ានយោបាយ.................................................................................... ៣

## កម្មវិធីនយោបាយជាយុទ្ធសាស្ត្រ ៩ ចំណុច

១- **បំរើ** : វិស័យសេដ្ឋកិច្ចជាតិដើម្បីលើកស្ទួយជីវភាព
របស់ប្រជាពលរដ្ឋដោយផ្តល់អាទិភាពលើវិស័យកសិកម្ម...................... ៣

២- **បំរើ** : វិស័យអប់រំដោយផ្តល់ឱកាសឱ្យកុមារ យុវជន និង
ពលរដ្ឋខ្មែរទូទៅ ទទួលបានការសិក្សាអប់រំគ្រប់ៗគ្នាដើម្បី
អនាគតរុងរឿង ....................................................................... ៤

៣- **បំរើ** : វិស័យសុខាភិបាលដោយ ធានាឱ្យប្រជាពលរដ្ឋខ្មែរគ្រប់រូប
ទទួលបានសេវាសុខាភិបាល និង សង្គមកិច្ច .................................... ៥

៤- **ការពារ** : សិទ្ធិអំណាចប្រជាពលរដ្ឋ............................................................. ៥

៥- **ការពារ** : ទ្រព្យសម្បត្តិជាតិ និង ការពារបរិស្ថាន............................................ ៦

៦- **ការពារ** : តម្លៃជាតិ អត្តសញ្ញាណជាតិ និង វប្បធម៌ប្រពៃណីជាតិខ្មែរ................. ៧

៧- **កសាង** : សង្គមប្រជាធិបតេយ្យសេរីពិតប្រាកដនៅកម្ពុជាដោយ
ទប់ស្កាត់នូវអំណាចផ្តាច់ការ ....................................................... ១១

៨- **កសាង** : សង្គមស្អាតស្អំ យុត្តិធម៌ដោយទប់ស្កាត់នូវអំពើពុករលួយ
និង អយុត្តិធម៌សង្គម.................................................................... ៨

៩- **កសាង** : ប្រទេសឱ្យមានឯករាជ្យភាព អធិបតេយ្យ និង បូរណភាពទឹកដីខ្មែរ
ឱ្យបានរឹងមាំ ដោយទប់ស្កាត់នូវការរំលោភឈ្លានពាន
ពីបរទេសតាមគ្រប់រូបភាព.......................................................... ៨

# គណបក្សសិទ្ធិមនុស្ស
## ( រដ្ឋាភិបាលរបស់ប្រជាពលរដ្ឋ )

## ១. ចក្ខុវិស័យ និង បេសកកម្ម

**គណបក្សសិទ្ធិមនុស្ស** នឹងកសាងប្រទេសកម្ពុជាឱ្យក្លាយជាប្រទេសមួយដែលមានឯករាជ្យភាព បូរណភាព អធិបតេយ្យភាពជាតិពេញលេញ និង ដែលប្រជាពលរដ្ឋខ្មែរគ្រប់ៗរូបមានឱកាសស្មើគ្នា ដើម្បីកសាងអនាគតរបស់ខ្លួនឱ្យបានថ្លៃថ្នូរសម្បូរសប្បាយ ។

## ២. គោលបំណង

**គណបក្សសិទ្ធិមនុស្ស** មានគោលបំណងប្រមូលផ្តុំកម្លាំងអ្នកស្នេហាជាតិ អ្នកស្រលាញ់លទ្ធិប្រជាធិបតេយ្យពិតប្រាកដទាំងក្នុងនិងក្រៅប្រទេសដើម្បីរួបរួមគ្នា បំរើ ការពារ និង កសាងប្រទេសតាមរយៈការលើកស្ទួយ និង ការពារនូវសិទ្ធិជាមូលដ្ឋានរបស់ប្រជា-ពលរដ្ឋសំខាន់មាន :

- សិទ្ធិរស់រានមានជីវិត
- សិទ្ធិទទួលបានសេរីភាព
- សិទ្ធិទទួលបានការអភិវឌ្ឍ

## ៣. បាវចនា

**គណបក្សសិទ្ធិមនុស្ស** មានបាវចនា **បំរើ ការពារ កសាង** ។

## ៤. រូបសញ្ញា

គណបក្សសិទ្ធិមនុស្ស មានរូបសញ្ញាព្រះចន្ទពេញវង់ពណ៌ស ក្នុងផ្ទៃចតុកោណកែងពណ៌បៃតង និង មានសរសេរអក្សរ គណបក្សសិទ្ធិមនុស្ស ។

អត្ថន័យរូបសញ្ញា :

- ព្រះចន្ទពេញវង់ បំភ្លឺមនុស្សទូទៅ ដោយបញ្ជាក់អំពីភាពមិនប្រកាន់រើសអើង ការផ្តល់ឱកាសនិងសិទ្ធិសេរីភាពស្មើៗគ្នាដល់ប្រជាពលរដ្ឋគ្រប់រូប និង តម្លាភាពក្នុងការគ្រប់គ្រង ។
- ព្រះចន្ទពេញវង់ ជាពន្លឺត្រជាក់ត្រជុំ ដែលបង្ហាញពីភាពអហិង្សា និង សន្តិភាពនិយម ។
- ព្រះចន្ទពេញវង់ ជាពន្លឺដែលមិនអាចរលត់ ទោះជាខ្យល់ព្យុះបក់បោកយ៉ាងណាក៏ដោយ នេះជាការបញ្ជាក់អំពីការតស៊ូដែលមិនរាថយ ។
- ពណ៌បៃតងតំណាងឱ្យធម្មជាតិ ដែលឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់គណបក្សលើបរិស្ថាន ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និង ការយកចិត្តទុកដាក់លើកសិករ ។

## ៥. មាគ៌ានយោបាយ

មាគ៌ានយោបាយរបស់**គណបក្សសិទ្ធិមនុស្ស** ឈរលើគោលការណ៍សំខាន់ៗចំនួន ៤ ( សសរទ្រូងទាំង ៤)

- **គណបក្សសិទ្ធិមនុស្ស** ប្រកាន់យកគោលការណ៍អហិង្សា (Non-Violence) ហើយដើរតាមមាគ៌ាកណ្តាល ដែលជាមាគ៌ា (Middle Path) របស់ព្រះពុទ្ធ ។
- **គណបក្សសិទ្ធិមនុស្ស** ប្រកាន់យកគោលការណ៍យុត្តិធម៌សង្គម (Social Justice) មានន័យថា រដ្ឋត្រូវធានាឱ្យប្រជាពលរដ្ឋទទួលបានឱកាសស្មើគ្នាខាងនយោបាយ ឱកាសស្មើគ្នាខាងសេដ្ឋកិច្ច និង ឱកាសស្មើគ្នាខាងសង្គមកិច្ច ។

- **គណបក្សសិទ្ធិមនុស្ស** ប្រកាន់យកគោលការណ៍ប្រជាធិបតេយ្យសេរី ប្រជាពលរដ្ឋជាម្ចាស់អំណាចដែលប្រជាពលរដ្ឋម្នាក់ៗ មិនមែនមានត្រឹមតែសិទ្ធិបោះឆ្នោតជ្រើសរើសអ្នកដឹកនាំប៉ុណ្ណោះទេ តែអាចមានសិទ្ធិចូលរួមក្នុងសកម្មភាពនយោបាយតាមគ្រប់រូបភាព ដើម្បីកែលម្អនូវគោលនយោបាយរបស់រដ្ឋាភិបាល និង មានសិទ្ធិដកអំណាចពីអ្នកដឹកនាំរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់មុនពេលចប់អាណត្តិ ។
- **គណបក្សសិទ្ធិមនុស្ស** ប្រកាន់យកគោលការណ៍និរន្តរភាព (Sustainability) មានន័យថា រក្សានូវតុល្យភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច (Economic Development) និង អភិរក្សធនធានធម្មជាតិ (Conservation) ដើម្បីមនុស្សលោកជំនាន់ក្រោយអាចទទួលផលប្រយោជន៍ពីធនធានធម្មជាតិ ដូចមនុស្សនាពេលបច្ចុប្បន្នដែរ ។

## កម្មវិធីនយោបាយជាអាទិភាព ៩ ចំណុច និង ៥៥ វិធានការ

រដ្ឋាភិបាលដែលដឹកនាំដោយគណបក្សសិទ្ធិមនុស្ស គឺជា " **រដ្ឋាភិបាលរបស់ប្រជាពលរដ្ឋ** " ។ ដើម្បីឆ្លើយតបទៅនឹងអត្ថន័យនេះ និង ដើម្បីឱ្យស្របទៅនឹងបាវចនា **ចំរើ ការពារ កសាង** គណបក្សសិទ្ធិមនុស្សបានសម្រេចដាក់ចេញនូវកម្មវិធីនយោបាយអាទិភាព **៩ ចំណុច** និង **៥៥ វិធានការ** ដែលក្នុងនោះ ចែកចេញជាបីផ្នែកធំៗគឺ :

- ផ្នែកទីមួយរួមមាន យុទ្ធសាស្ត្រទី **១, ២, ៣** គឺជាយុទ្ធសាស្ត្រ **ចំរើ**
- ផ្នែកទីពីររួមមាន យុទ្ធសាស្ត្រទី **៤, ៥, ៦** គឺជាយុទ្ធសាស្ត្រ **ការពារ**
- ផ្នែកទីបីរួមមាន យុទ្ធសាស្ត្រទី **៧, ៨, ៩** គឺជាយុទ្ធសាស្ត្រ **កសាង**

## ផ្នែកទីមួយ : ចំរើ

### ១~ ចំរើ : <u>វិស័យសេដ្ឋកិច្ចជាតិដើម្បីលើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋដោយផ្តល់អាទិភាពលើវិស័យកសិកម្ម</u>

(១)- កែទម្រង់ដីធ្លី :

- រដ្ឋត្រូវចុះទៅធ្វើកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋឱ្យបានគ្រប់ៗគ្នានិងឱ្យបានឆាប់រហ័សដើម្បី ធានាថាប្រជាពលរដ្ឋជាម្ចាស់កម្មសិទ្ធិដីធ្លីស្របច្បាប់ដែលមិនអាចឱ្យអ្នកណារឹបអូសបាន ។
- រដ្ឋផ្តល់គម្រោងគាំទ្រ ពិសេសសម្រាប់អភិវឌ្ឍនូវតំបន់សម្បទានសង្គមកិច្ចជូនប្រជាកសិករដែលទៅរស់នៅតំបន់នោះ ។
- តម្រូវឱ្យអ្នកដែលមានដីច្រើន ហើយដែលមិនបង្កបង្កើនផលបង់ពន្ធជូនរដ្ឋ ដើម្បីយកទៅជួយដល់ការអភិវឌ្ឍក្នុងមូលដ្ឋាន ។
- ផ្តល់ដីជូនកសិករដែលខ្វះដីបង្កបង្កើនផល តាមរយៈការផ្ទេរដីសម្បទានសេដ្ឋកិច្ចដែលកាន់កាប់ដោយក្រុមហ៊ុនធំៗឱ្យទៅជាដីសម្បទានសង្គមកិច្ចកាន់កាប់ដោយកសិករផ្ទាល់វិញ ។ លើកលែងដីសម្បទានទាំងឡាយណាដែលបានផ្តល់ផលប្រយោជន៍សមរម្យដល់ជាតិនិងប្រជាពលរដ្ឋខ្មែរ ។

(២)- ធានាឱ្យកសិករមានប្រព័ន្ធធារាសាស្ត្រគ្រប់ទីកន្លែង ដោយរដ្ឋផ្តល់ទុនវិនិយោគចំនួន ១០០លានដុល្លា ក្នុងមួយឆ្នាំនិងផ្តល់ការគាំទ្រឱ្យបានពេញលេញ ដល់សហគមន៍ក្នុងការគ្រប់គ្រងថែរក្សាឱ្យបានគង់វង្សយូរអង្វែង ដើម្បីឱ្យកសិករមានទឹកស្រោចស្រពដំណាំដោយមិនរង់ចាំតែទឹកភ្លៀង ។

(៣)- ធានាផ្តល់ទុនកម្ចីរយៈពេលវែងដោយមានការប្រាក់ទាប រួមទាំងមានពូជ ជី ថ្នាំ ប្រេងឥន្ធនៈ និង ឧបករណ៍កសិកម្មមានគុណភាពនិងមានតម្លៃថោក។ លើសពីនេះ ពូជ ជី ថ្នាំ និង ឧបករណ៍កសិកម្មទាំងអស់ដែលកំពុងដាក់លក់នៅលើទីផ្សារតម្រូវឱ្យសរសេរពន្យល់ជាភាសាខ្មែរ។

(៤)- ធានាផ្តល់ជូនកសិករនូវ : អ្នកបច្ចេកទេសកសិកម្ម - ពេទ្យសត្វបំរើកសិករគ្រប់ទីកន្លែង - ស្ថានីយពិសោធន៍ និង កន្លែងធ្វើបង្ហាញដើម្បីឱ្យកសិករបានរៀនសូត្រ និង មូលនិធិសម្រាប់ទស្សនកិច្ចសិក្សានៅក្នុង និង ក្រៅប្រទេស។

(៥)- ធានាឱ្យកសិករមានទីផ្សារលក់ផលិតផលបានតម្លៃខ្ពស់ តាមរយៈការចងក្រង និង ពង្រឹងសមាគមអ្នកផលិត។ រៀបចំឱ្យមានទីផ្សារកសិករ (ផ្សារណាត់) បានគ្រប់ទីកន្លែង។ រដ្ឋធានាផ្តល់ទុនឱ្យសមាគមសម្រាប់ទិញផលិតផលស្តុកទុក និងផ្តល់ពត៌មានអំពីតម្លៃទីផ្សារក្នុង-ក្រៅប្រទេស ជួយសម្រួលក្នុងការនាំចេញកសិផល។ លើកតម្កើងផលិតផលក្នុងស្រុកតាមគ្រប់រូបភាព ហើយក្នុងករណីចាំបាច់ទប់ស្កាត់ការនាំចូលពីក្រៅប្រទេស នូវកសិផលណាដែលកសិករក្នុងស្រុកអាចផលិតបាន។

(៦)- គាំទ្រឱ្យមានសមាជកសិករថ្នាក់ខេត្ត និង ថ្នាក់ជាតិ ជារៀងរាល់ឆ្នាំ ដើម្បីផ្តល់ឱកាសឱ្យកសិករបានរៀនសូត្រពីគ្នាទៅវិញទៅមក និង ផ្តល់យោបល់ពីគោលនយោបាយកសិកម្មរបស់រដ្ឋាភិបាល។

(៧)- គាំទ្រនិងជំរុញឱ្យមានប្រព័ន្ធធានារ៉ាប់រងដល់មុខរបរខ្នាតតូច មធ្យមនិងខ្នាតធំ ដើម្បីការពារការក្ស័យធនដោយអភូតហេតុផ្សេងៗ។

(៨)- បង្កភាពងាយស្រួល និង លើកទឹកចិត្តដល់រោងចក្រ សហគ្រាស សិប្បកម្ម អាជីវកម្មគ្រប់ប្រភេទ ជាពិសេស មុខរបរខ្នាតតូចនិងមធ្យម តាមរយៈការផ្តល់ទុនរយៈពេលវែងដោយយកការប្រាក់ទាប។ ផ្តល់ការបណ្តុះបណ្តាលពិគ្រោះយោបល់ដោយឥតគិតថ្លៃ បំបាត់ការិយាធិបតេយ្យ និង ការគាបសង្កត់យកលុយពីសំណាក់ អាជ្ញាធរសមត្ថកិច្ច។

(៩)- ធ្វើការកែលម្អតំបន់ទេសចរណ៍ដែលមានស្រាប់ ដោយពង្រីកការអភិវឌ្ឍន៍តំបន់ទេសចរណ៍វប្បធម៌ ធម្មជាតិ និង សិប្បនិម្មិតឱ្យបានច្រើនកន្លែងដើម្បីផ្តល់ការងារ និង ប្រាក់ចំណូលជូនប្រជាពលរដ្ឋ ជាពិសេសអ្នករស់នៅ ជុំវិញតំបន់ទេសចរណ៍។ ចំពោះតំបន់ទេសចរណ៍ជាតិធំៗត្រូវរៀបចំឱ្យមានការគ្រប់គ្រងដោយមានការដេញថ្លៃដោយតម្លាភាព ដើម្បីទាញចំណូលចូលរដ្ឋឱ្យបានជាអតិបរមា។

(១០)- ទប់ស្កាត់ទំនិញឡើងថ្លៃ ដោយបញ្ចុះថ្លៃប្រេងឥន្ធនៈឱ្យមានតម្លៃប្រហាក់ប្រហែលប្រទេសជិតខាង និង បញ្ចុះថ្លៃអគ្គិសនីឱ្យនៅត្រឹម ៣០០-៥០០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង។ បញ្ចុះតម្លៃជីនិងចំណីសត្វ តាមរយៈបង្កើនការផលិតក្នុងស្រុក។

(១១)- បន្ថយពន្ធលើប្រភេទទំនិញ និង សេវាប្រើប្រាស់ចាំបាច់ដែលប្រជាពលរដ្ឋក្រីក្រភាគច្រើនត្រូវការជាប្រចាំ ដែលជំនួសដោយបង្កើនពន្ធទៅលើប្រភេទទំនិញប្រណិត ឬ ដែលអាចប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ និង សេវាកម្មណាដែលមិនចាំបាច់ដូចជា រថយន្តទំនើបៗ ស្រា បារីថ្លៃៗ ដែលនាំមកពីក្រៅប្រទេសជាដើម។

(១២)- ពង្រីកការសាងសង់ផ្លូវ ស្ពាន ឱ្យបានដល់តំបន់ដាច់ស្រយាល និង ពង្រឹងគុណភាពផ្លូវ ស្ពាន ឱ្យប្រើប្រាស់បានយូរដោយធ្វើការត្រួតពិនិត្យគុណភាពបច្ចេកទេសក្នុងការសាងសង់ និង ឱ្យមានសេវាថែរក្សាជាប្រចាំ ។

## ២. បំពេ : **វិស័យអប់រំដោយផ្តល់ឱកាសឱ្យកុមារ យុវជន និង ពលរដ្ឋខ្មែរទូទៅទទួលបានការសិក្សាអប់រំគ្រប់ៗគ្នា ដើម្បីអនាគតរុងរឿង**

(១៣)- លើកស្ទួយវិស័យអប់រំ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដោយចំណាយថវិកាជាតិលើសពីពាក់កណ្តាលទៅលើវិស័យអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរ ជាពិសេស យុវជនមានចំណេះដឹង ជំនាញពិតប្រាកដ ដើម្បីទទួលបានការងារធ្វើនិងទទួល បានប្រាក់ចំណូលខ្ពស់។

(១៤)- រដ្ឋាភិបាលដឹកនាំដោយគណបក្សសិទ្ធិមនុស្ស មិនបណ្តោយឱ្យយុវជនណាម្នាក់គ្មានចំណេះ ឬ ជំនាញក្នុងខ្លួនឡើយ។ ចំពោះយុវជនដែលមិនចង់បន្តការសិក្សានៅមហាវិទ្យាល័យ រដ្ឋផ្តល់ជូននូវការបណ្តុះបណ្តាលចំណេះដឹង វិជ្ជាជីវៈជំនាញ ឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការទីផ្សារការងារ ដើម្បីអាចយកទៅប្រកបមុខរបរចិញ្ចឹមជីវិត ដោយរដ្ឋធានាផ្តល់ជូននូវប្រាក់កម្ចីសម្រាប់ធ្វើដើមទុន និង មានសេវាប្រឹក្សាយោបល់។

(១៥)- ជំរុញកម្មវិធីផ្តល់ប្រាក់កម្ចីឱ្យបានយ៉ាងតិចបំផុត ៥ម៉ឺននាក់ ក្នុង១ឆ្នាំ សម្រាប់និស្សិតក្រីក្រដែលចង់បន្តការសិក្សានៅតាមមហាវិទ្យាល័យ ហើយអាចសងរដ្ឋវិញជាដំណាក់កាលបន្តិចម្តងៗ ក្នុងចន្លោះពេលពី ១៥-៣០ ឆ្នាំ ក្រោយពេលបញ្ចប់ការសិក្សាហើយមានការងារធ្វើ និង មានសមត្ថភាពរកប្រាក់ចំណូលបាន។

(១៦)- បង្កើនកម្មវិធីអាហារូបករណ៍ទាំងក្នុង និង ក្រៅប្រទេសឱ្យបាន ១ម៉ឺន នាក់ ក្នុង១ឆ្នាំ សម្រាប់សិស្សនិស្សិតរៀនពូកែ។

(១៧)- ជំរុញនិងលើកទឹកចិត្តឱ្យមានសាកលវិទ្យាល័យនៅគ្រប់ខេត្តក្រុងតាមជនបទ ដើម្បីបង្កភាពងាយស្រួលដល់កូនអ្នកជនបទ។ កសាងនិងពង្រាយសាលារៀនគ្រប់កម្រិតឱ្យស្របតាមបរិមាណសិស្ស និង តាមតំបន់ភូមិសាស្ត្រដោយមានគម្រោងផែនការជាក់លាក់។ ជំរុញឱ្យមានមតេយ្យសាលាសម្រាប់អប់រំ និង ថែរក្សាកូនក្មេងឱ្យបាន គ្រប់ភូមិ។

(១៨)- លើកកម្ពស់តម្លៃគ្រូបង្រៀន ដោយដំឡើងប្រាក់បៀវត្សជូនលោកគ្រូ អ្នកគ្រូ យ៉ាងតិច ៦០០០០០ រៀលក្នុង មួយខែ និង ផ្តល់ថវិកាសម្រាប់សិក្សាស្រាវជ្រាវឱ្យបានគ្រប់គ្រាន់។ ផ្តល់ជូនប្រាក់ឧបត្ថម្ភបន្ថែមចំពោះលោកគ្រូ អ្នកគ្រូដែលស្ម័គ្រចិត្តទៅបង្រៀននៅតំបន់ជនបទដាច់ស្រយាល។ ពង្រឹងគុណភាពអប់រំតាមរយៈពង្រឹងក្រមសីលធម៌ និង ពង្រឹងសមត្ថភាពលោកគ្រូ អ្នកគ្រូ។

## ៣. ចំរើ : វិស័យសុខាភិបាល ដោយធានាឱ្យប្រជាពលរដ្ឋខ្មែរគ្រប់រូបទទួលបានសេវាសុខាភិបាល និង សង្គមកិច្ច

(១៩)- ពង្រឹងវិស័យសុខាភិបាលដោយរៀបចំឱ្យមានប្រព័ន្ធធានារ៉ាប់រងសុខភាពមួយ ដែលមិនធ្លាប់មានពីមុនមក ជាពិសេសដល់អ្នកក្រីក្រនៅជនបទ តាមរយៈការចូលរួមពីប្រជាពលរដ្ឋ ៥០០រៀល ក្នុងមួយខែ តែទទួលបានការពិនិត្យ និង ព្យាបាលជំងឺដោយមិនបង់ប្រាក់។

(២០)- កសាងមន្ទីរពេទ្យ និង មណ្ឌលសុខភាព ឱ្យស្របតាមតម្រូវការ និង ចំនួនប្រជាពលរដ្ឋក្នុងភូមិ-ស្រុក ដោយមានបុគ្គលិកពេទ្យមានសមត្ថភាព និង ការទទួលខុសត្រូវពិតប្រាកដធ្វើការពេញម៉ោង មានថ្នាំព្យាបាល មានឧបករណ៍ ពេទ្យទំនើប និង មានអគ្គិសនី ទឹកស្អាតគ្រប់គ្រាន់តាមតម្រូវការប្រើប្រាស់ក្នុងមន្ទីរពេទ្យ។ ពង្រឹងសីលធម៌ និង លើកទឹកចិត្តគ្រូពេទ្យដោយដំឡើងប្រាក់បៀវត្សឱ្យបានសមរម្យ និង ផ្តល់ថវិកាស្រាវជ្រាវបន្ថែម។

(២១)- ធានាឱ្យផលិតផលធ្វើចរាចរលើទីផ្សារ ត្រូវបានត្រួតពិនិត្យដោយស្ថាប័នជំនាញយ៉ាងហ្មត់ចត់ ដើម្បីការពារដល់សុវត្ថិភាពចំណីអាហារដល់អ្នកបរិភោគ។

(២២)- ធានាឱ្យមានប្រព័ន្ធទឹកស្អាតតាមទីប្រជុំជនទូទាំងប្រទេស និង ធានាឱ្យមានឧបករណ៍ចម្រាញ់ទឹកស្អាតគ្រប់គ្រួសារសម្រាប់ប្រជាពលរដ្ឋរស់នៅតំបន់ដាច់ស្រយាល។

(២៣)- ធានាឱ្យមានការគោរពពេញលេញនូវសិទ្ធិការងាររបស់បុគ្គលិក និង កម្មករ។ ចំពោះបុគ្គលិកកម្មករដែលអស់ការងារធ្វើក្នុងរយៈពេលកំណត់មួយ ត្រូវទទួលបានប្រាក់ឧបត្ថម្ភពីប្រព័ន្ធធានារ៉ាប់រងសង្គមមួយដែលបង្កើតឡើងសម្រាប់ការពារផលប្រយោជន៍បុគ្គលិក កម្មករ។

(២៤)- លើកស្ទួយសិទ្ធិទទួលបានជម្រករស់នៅសមរម្យ ដោយបង្កើតឱ្យមានប្រព័ន្ធប្រាក់កម្ចីសម្រាប់សាងសង់ផ្ទះសំបែងដោយយកការប្រាក់ទាប និង សងរំលស់វិញរយៈពេលវែង ជាពិសេសសម្រាប់គ្រួសារក្រីក្រដែលខ្វះផ្ទះសំបែងរស់នៅសមរម្យ។ សម្រាប់ចាស់ជរា ជនពិការ ក្មេងកំព្រា រដ្ឋធានាឱ្យមាន មជ្ឈមណ្ឌលសម្រាប់ស្នាក់នៅ ហូបចុក និង ព្យាបាលដោយឥតគិតថ្លៃ។

# ផ្នែកទីពីរ : ការពារ

## ៤. ការពារ : សិទ្ធិអំណាចប្រជាពលរដ្ឋ

(២៥)- ធានាការពារសេរីភាពក្នុងការបង្កើត អង្គការ សមាគម សហជីព សេរីភាពសារព័ត៌មាន សេរីភាព ធ្វើបាតុកម្ម កូដកម្ម ដោយសន្តិវិធី និង ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ។

(២៦)- ធានាការពារសិទ្ធិខ្មែរកម្ពុជាក្រោម ខ្មែរឥស្លាម ខ្មែរលើ និង ជនជាតិភាគតិច ដែលរស់នៅលើទឹកដីកម្ពុជាស្របច្បាប់ឱ្យមានសិទ្ធិសេរីភាពដូចពលរដ្ឋខ្មែរទូទៅ។

(២៧)- ផ្តល់សច្ចាប័នលើពិធីសារទី១ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដើម្បីបើកផ្លូវតវ៉ាទៅអង្គការសហប្រជាជាតិ អំពីការរំលោភសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ។ ជំរុញឱ្យបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ និង តំបន់ឱ្យមានប្រសិទ្ធភាព និង ឯករាជ្យភាពពិតប្រាកដ ដើម្បីធានាលើកស្ទួយ និង ការពារសិទ្ធិមនុស្សឱ្យបាន។

(២៨)- ស្ថាប័នសាធារណៈ មន្ត្រីរាជការ មន្ត្រីតុលាការ កងកម្លាំងប្រដាប់អាវុធទាំងអស់ត្រូវបំពេញមុខនាទី ជាអ្នកបំរើការពារប្រជាពលរដ្ឋដោយអព្យាក្រឹត មិនត្រូវធ្វើជាឧបករណ៏ផ្ទាល់របស់បុគ្គល ឬ គណបក្សនយោបាយណាមួយឡើយ។

(២៩)- រៀបចំឱ្យមានច្បាប់សម្រាប់ដាក់ពិន័យ និង ផ្តន្ទាទោសដល់អាជ្ញាធរ និង សមត្ថកិច្ចសាធារណៈដែលមិនបានឆ្លើយតបចំពោះសំណូមពរ សំណើ និង បណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋឱ្យទាន់ពេល ឬ ដោយគាបសង្កត់យកលុយពីប្រជាពលរដ្ឋ។ ទទួលស្គាល់ លើកតម្កើង ផ្តល់រង្វាន់ដល់មន្ត្រីរាជការ ដែលធ្វើការប្រកបដោយប្រសិទ្ធភាពស្អាតស្អំប្រកបដោយសីលធម៌។

(៣០)- បើកទូលាយឱ្យមានការចូលរួមពីប្រជាពលរដ្ឋខ្មែរ និង សង្គមស៊ីវិលគ្រប់មូលដ្ឋាន ក្នុងការចូលរួមកសាងជាតិ ដូចជាបើកឱកាសពិគ្រោះយោបល់គ្នាឱ្យបានទៀងទាត់លើបញ្ហាប្រទេសជាតិគ្រប់វិស័យ។

(៣១)- មិនចាត់ទុកខ្មែរណាជាសត្រូវស្លាប់រស់ មិនប្រកាន់និន្នាការនយោបាយ និង មិនរើសអើងគណបក្សនយោបាយ ជាពិសេសមិនគាបសង្កត់មន្ត្រីរាជការកម្លាំងប្រដាប់អាវុធឱ្យគាំទ្របក្សនយោបាយខ្លួន និង មិនដកហូតមុខតំណែង ដោយសារហេតុផលនយោបាយឡើយ។

## ៥. ការពារទ្រព្យសម្បត្តិជាតិ និង ការពារបរិស្ថាន

(៣២)- ធ្វើបញ្ជីទ្រព្យសម្បត្តិធនធានរបស់ជាតិឱ្យបានច្បាស់លាស់ជាបន្ទាន់ និង ដោយតម្លាភាព ហើយយកដាក់ជា សម្បត្តិរដ្ឋវិញនូវ បឹង ដី ព្រៃឈើ និង អគារ របស់រដ្ឋ ដែលអ្នកមានអំណាចរំលោភយកដោយខុសច្បាប់។

(៣៣)- ធ្វើច្បាប់គ្រប់គ្រងធនធានធម្មជាតិ ដូចជា រ៉ែ ប្រេងកាត ត្បូង មាស ទង់ដែង ដែក និង ព្រៃឈើ ឱ្យមានប្រសិទ្ធភាព និងដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅ។

(៣៤)- រាល់ការរុករក និង ធ្វើអាជីវកម្មរ៉ែ ត្រូវដាក់ឱ្យមានការដេញថ្លៃពីក្រុមហ៊ុនឯកជននានាដោយមានតម្លាភាព ហើយរដ្ឋ និងក្រុមហ៊ុនត្រូវប្រកាសពីចំណូល និង ចំណាយជាប្រចាំ និង ជាសាធារណៈ។

(៣៥)- រាល់ការអនុវត្តអាជីវកម្មរ៉ែ ការសាងសង់វារីអគ្គិសនី ការសាងសង់រោងចក្រ សហគ្រាស និង ហេដ្ឋារចនាសម្ព័ន្ធ ធំៗផ្សេងៗត្រូវតែមានការសិក្សាអំពីផលប៉ះពាល់បរិស្ថានសង្គម និង បរិស្ថានធម្មជាតិឱ្យបានច្បាស់លាស់ជាមុនសិន។

(៣៦)- ការពារឱ្យមាននិរន្តរភាពធនធានធម្មជាតិ និង និរន្តរភាព បរិស្ថានធម្មជាតិ តាមរយៈ :

- ទប់ស្កាត់ការនេសាទខុសច្បាប់ បង្កើតឱ្យមានតំបន់អភិរក្សត្រីធម្មជាតិ និង រៀបចំពង្រឹង សហគមន៍ នេសាទ ដើម្បីគ្រប់គ្រងដែននេសាទប្រកបដោយប្រសិទ្ធភាព។
- ស្តារប្រព័ន្ធផ្លូវទឹកធម្មជាតិដូចជា ទន្លេ ព្រែក ស្ទឹង ដែលជា ជម្រកត្រី និង ជាប្រព័ន្ធដឹកជញ្ជូនផ្លូវទឹកទៀតផង។
- បញ្ឈប់ការផ្តល់ព្រៃសម្បទាន និង ដីសម្បទាន ដល់ក្រុមហ៊ុនឯកជន និង ពង្រីកសហគមន៍ ព្រៃឈើ ដើម្បីគ្រប់គ្រង និង ប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាព (ឱ្យបានយូរអង្វែងមិនហិនហោច)។
- ចាត់វិធានការម៉ឺងម៉ាត់ទប់ស្កាត់ការកាប់ និង នាំឈើប្រណីតចេញទៅក្រៅប្រទេស និង ទប់ស្កាត់ការជួញដូរសត្វព្រៃគ្រប់ប្រភេទ។
- រដ្ឋចាត់វិធានការដាំដើមឈើទូទាំងប្រទេសឡើងវិញ ជាពិសេស នៅតាមតំបន់ព្រៃភ្នំដែលត្រូវគេកាប់បំផ្លាញ និងបំផុសឱ្យមានការចូលរួមថែទាំទាំងអស់គ្នា ដើម្បីការពារបរិស្ថាននិងបញ្ចៀសគ្រោះធម្មជាតិ ដូចជា ព្យុះ ទឹកជំនន់ និងភាពរាំងស្ងួត ហើយព្រៃឈើក៏ជួយ ផ្តល់របបទឹកភ្លៀងទៀងទាត់ និង គ្រប់គ្រាន់អំណោយផល ដល់វិស័យកសិកម្មផងដែរ។

## ៦. ការពារតម្លៃជាតិ អត្តសញ្ញាណជាតិ និង វប្បធម៌ប្រពៃណីជាតិខ្មែរ

(៣៧) - អ្នកដឹកនាំសំខាន់ៗត្រូវមានដើមកំណើតជាខ្មែរ ដោយឡែកនាយករដ្ឋមន្ត្រីត្រូវមានឪពុក-ម្ដាយ ដើមកំណើតជាខ្មែរ ។

(៣៨) - បង្កើតវប្បធម៌សន្ទនាគ្នា រវាងគណបក្សនយោបាយនានា ជាពិសេស រវាងគណបក្សកាន់អំណាច និង គណបក្សប្រឆាំង ។

(៣៩) - បណ្ដុះបណ្ដាល និង ផ្សព្វផ្សាយវប្បធម៌អហិង្សា ការអត់ឱនអធ្យាស្រ័យ និង ការសន្ទនាគ្នាជាចម្បង ។

(៤០) - អប់រំ និង ផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវសីលធម៌ វប្បធម៌ ពលរដ្ឋវិជ្ជា អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ ប្រពៃណី ទំនៀមទម្លាប់ សាសនាជាតិ និង ស្មារតីស្នេហាជាតិ តាមរយៈកម្មវិធីសិក្សា សិល្បៈ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន និង ផ្ទាំងផ្សព្វផ្សាយសាធារណៈ ។

(៤១) - ចាត់វិធានការដើម្បីលុបបំបាត់ការជួញដូរមនុស្ស គ្រឿងញៀន ល្បែងស៊ីសងគ្រប់ ប្រភេទ អំពើហិង្សា ក្នុងគ្រួសារ បងតូច បងធំ និង អំពើពាលាដទៃទៀត ។

# ផ្នែកទីបី : កសាង

## ៧. កសាងសង្គមប្រជាធិបតេយ្យសេរីពិតប្រាកដនៅកម្ពុជា ដោយទប់ស្កាត់នូវអំណាចផ្ដាច់ការ

(៤២) - កំណត់អាណត្តិនាយករដ្ឋមន្ត្រី ដោយបុគ្គលម្នាក់មិនអនុញ្ញាតឱ្យធ្វើនាយករដ្ឋមន្ត្រីលើសពី ២អាណត្តិ ឬ ១០ឆ្នាំ ។ កាត់បន្ថយចំនួនអង្គរក្សរបស់នាយករដ្ឋមន្ត្រីនិងអង្គរក្សថ្នាក់ដឹកនាំដទៃទៀត ដោយតម្រូវឱ្យអង្គរក្សថ្នាក់ដឹកនាំរដ្ឋស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័នរដ្ឋ ។

(៤៣) - ពង្រឹងស្ថាប័នប្រជាធិបតេយ្យ និង ធ្វើឱ្យមានតុល្យភាពអំណាច និង បែងចែកអំណាចដាច់ពីគ្នារវាងអំណាច នីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និង តុលាការ ។ បែងចែកឱ្យដាច់ពីគ្នាក្នុងការគ្រប់គ្រងរដ្ឋនិងបក្ស ។

(៤៤) - បង្កើតនូវវប្បធម៌ប្រជាធិបតេយ្យដោយផ្ទាល់ ដោយបើកឱ្យមានវេទិកាជាផ្លូវការជួបសួរដេញដោលជាសាធារណៈរវាងអ្នកដឹកនាំរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ជាមួយប្រជាពលរដ្ឋ និង ឱ្យមានសមាជជាតិប្រចាំឆ្នាំ ក្នុងការសម្រេចបញ្ហាធំៗរបស់ជាតិអនុញ្ញាតឱ្យមានការចូលរួមផ្ទាល់ពីប្រជាពលរដ្ឋដោយធ្វើប្រជាមតិជាដើម ។

(៤៥) - បង្កើតនូវក្រមសីលធម៌សម្រាប់អ្នកដឹកនាំ ដោយតម្រូវឱ្យអ្នកដឹកនាំដែលមានកំហុសធ្ងន់ ប៉ះពាល់ដល់ផលប្រយោជន៍ប្រទេសជាតិ ឬដល់ប្រយោជន៍ប្រជាពលរដ្ឋក្នុងកម្រិតណាមួយត្រូវលាឈប់ពីមុខតំណែង ។ ផ្ដល់ឱកាសឱ្យប្រជាពលរដ្ឋ ធ្វើញត្តិទាមទារទម្លាក់អ្នកដឹកនាំពីមុខតំណែងក្នុងចំនួនកំណត់ណាមួយដែលរដ្ឋសភា ត្រូវយកទៅជជែកសួរដេញដោលដើម្បីដកសេចក្ដីទុកចិត្ត " ដកមុខតំណែង " ។

(៤៦) - កែប្រព័ន្ធបោះឆ្នោតឱ្យទៅជាប្រព័ន្ធឯកត្តនាម ឬ ប្រព័ន្ធចម្រុះ និង ឱ្យមានបេក្ខជនឯករាជអាចឈរឈ្មោះបាន ។ ឱ្យប្រជាពលរដ្ឋជាអ្នកបោះឆ្នោតដោយផ្ទាល់ (បោះឆ្នោតសកល) ជ្រើសរើសប្រធានភូមិ មេឃុំ ចៅសង្កាត់ អភិបាល ស្រុក/ខណ្ឌ អភិបាលខេត្ត/ក្រុង និង ចៅក្រមនៃតុលាការ ។

(៤៧) - កែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាពិសេស សមាសភាព គ.ជ.ប. មិនត្រូវជ្រើសចេញពីគណបក្សនយោបាយឡើយ គឺត្រូវជ្រើសចេញពីមជ្ឈដ្ឋានឯករាជ្យ ដើម្បីធានាការអនុវត្តការងារដោយមិនចំណុះឱ្យគណបក្សនយោបាយ ឬ បុគ្គលណាមួយឡើយ ។

(៤៨) - កាត់បន្ថយចំនួនឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អភិបាលរងខេត្តក្រុង អភិបាលរងស្រុកខណ្ឌ អាជ្ញាធរជាតិ ទីប្រឹក្សា និង អង្គរក្សអ្នកដឹកនាំបច្ចុប្បន្នឱ្យ នៅចំនួនអប្បបរមា ដើម្បីកាត់បន្ថយចំណាយដែលជាបន្ទុករបស់រដ្ឋ ។ លុបបំបាត់ចោលក្រសួង ទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីកាត់បន្ថយការប្រមូលផ្ដុំអំណាចលើបុគ្គល និង កាត់បន្ថយការិយាធិបតេយ្យ ។

## ៨- <u>កសាងសង្គម ស្អាតស្អំ យុត្តិធម៌ ដោយទប់ស្កាត់នូវអំពើពុករលួយ និង អយុត្តិធម៌សង្គម</u>

(៤៩)- ធ្វើច្បាប់ប្រឆាំងអំពើពុករលួយស្របតាមស្តង់ដារអន្តរជាតិ និង អនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធភាព។ បោសសម្អាតអំពើពុករលួយពីលើចុះក្រោម និង តម្រូវឱ្យអ្នកដឹកនាំសំខាន់ៗប្រកាសទ្រព្យសម្បត្តិមុន និង ក្រោយកាន់តំណែង។

(៥០)- បង្កើនប្រសិទ្ធភាពរដ្ឋបាលសាធារណៈ ដោយផ្តល់ជូនមន្ត្រីរាជការ និង កងកម្លាំងប្រដាប់អាវុធឱ្យទទួលបានប្រាក់បៀវត្សយ៉ាងតិច ៤០០០០០រៀល ក្នុងមួយខែ និង ផ្តល់មុខងារ និង តួនាទីទៅតាមគុណសម្បត្តិការងារ។ រាល់ការជ្រើសរើសមន្ត្រីបុគ្គលិករបស់រដ្ឋត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងដោយតម្លាភាព ជៀសវាង ការសូកប៉ាន់ និង បក្សពួក។

(៥១)- កែទម្រង់ប្រព័ន្ធយុត្តិធម៌ : ដោយលើកកម្ពស់តុលាការមិនឱ្យស្ថិតនៅក្រោមអំណាចបុគ្គល អំណាចគណបក្សនយោបាយ ឬ អំណាចនីតិប្រតិបត្តិ ឬ អំណាចនីតិប្បញ្ញត្តិឡើយ។ ទប់ស្កាត់អំពើពុករលួយរបស់ចៅក្រម ព្រះរាជអាជ្ញា និង មន្ត្រីតុលាការផ្សេងទៀត។ កែទម្រង់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមរយៈការបង្កើតសហលក្ខន្តិកៈសម្រាប់ចៅក្រម ព្រះរាជអាជ្ញាជាបន្ទាន់ ដើម្បីធានាឯករាជ្យភាពប្រសិទ្ធភាពនិងយុត្តិធម៌ជូនសង្គមជាតិ និង ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈដោយមិនរើសអើង ឬ ប្រកាន់បក្សពួកឡើយ ។

## ៩- <u>កសាងប្រទេសឱ្យមានឯករាជ្យភាព អធិបតេយ្យ និង បូរណភាពទឹកដីខ្មែរឱ្យបានរឹងមាំ ដោយទប់ស្កាត់នូវការរំលោភឈ្លានពានពីបរទេសតាមគ្រប់រូបភាព</u>

(៥២)- ការពារជាដាច់ខាតនូវព្រំដែនប្រទេសកម្ពុជានិងមិនទទួលស្គាល់ព្រំដែន ឬ សន្ធិសញ្ញាណាដែលធ្វើឱ្យបាត់បង់ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ។

(៥៣)- ចាត់វិធានការបង្ការ និង ការពារព្រំដែនដោយសន្តិវិធី ដោយអភិវឌ្ឍតាមបណ្តោយព្រំដែន ដូចជាផ្តល់ការផ្គត់ផ្គង់ទឹក ភ្លើង សាងសង់ផ្លូវថ្នល់ ស្ពាន មន្ទីរពេទ្យ សាលារៀន វត្តអារាម និង ផ្សារជាដើម ដើម្បីលើកទឹកចិត្តឱ្យប្រជាពលរដ្ឋខ្មែរទូទៅរស់នៅតាមព្រំដែនឱ្យបានកាន់តែច្រើន។

(៥៤)- ចាត់វិធានការឱ្យទាន់ពេលតាមផ្លូវច្បាប់ដោយអហិង្សានិងម៉ឺងម៉ាត់ ចំពោះជនអន្តោប្រវេសន៍ដែលមករស់នៅខុសច្បាប់តាមរយៈការស្រាវជ្រាវស៊ើបអង្កេតឱ្យបានច្បាស់លាស់ និង ពិនិត្យសើរើឡើងវិញ ចំពោះអត្តសញ្ញាណប័ណ្ណ និង លិខិតស្នាមនានា ដែលបានផ្តល់ឱ្យជនអន្តោប្រវេសន៍ដោយសមត្ថកិច្ចពុករលួយកន្លងទៅ។

(៥៥)- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការអន្តរជាតិ ជាមួយនឹងរដ្ឋាភិបាលប្រទេសនានាក្នុងពិភពលោកដោយឈរលើស្មារតីគោរពអធិបតេយ្យគ្នាទៅវិញទៅមក។ បង្កើននូវតួនាទីរបស់កម្ពុជាក្នុងការបំពេញបេសកកម្ម សន្តិភាពក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ ក៏ដូចជាក្នុងការជំរុញក្នុងការអនុវត្តលទ្ធិប្រជាធិបតេយ្យ និង ការគោរពសិទ្ធិមនុស្សឱ្យបានទូលំទូលាយនៅលើពិភពលោក។

| | | |
|---|---|---|
| ១១ | គណបក្សសិទ្ធិមនុស្ស | ✓ |